# ជំនួយបច្ចេកទេសក្នុងការកសាងសមត្ថភាពថ្នាក់តំបន់
# ការពង្រឹងសមត្ថភាពផ្នែកនីតិបរិស្ថាននៅអាស៊ីប៉ាស៊ីហ្វិកៈ ការអភិវឌ្ឍជើងឯកផ្នែកនីតិបរិស្ថាន
# កម្មវិធីការបណ្តុះបណ្តាលគ្រូបង្គោល

**ថ្ងៃទី ២៧ ខែ វិច្ឆិកា - ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៧**

**ខេត្តសៀមរាប ប្រទេសកម្ពុជា**

## កំណត់ហេតុឆ្លុះបញ្ចាំង

### សេចក្តីផ្តើម

ការប្រើប្រាស់កំណត់ហេតុឆ្លុះបញ្ចាំង គឺជាបច្ចេកទេសមួយ ទាំងសម្រាប់និស្សិតថ្នាក់បរិញ្ញាបត្រ និងក្រោយបរិញ្ញាបត្រ ដើម្បីកត់ត្រាចំណាប់អារម្មណ៍របស់ខ្លួនលើប្រធានបទវគ្គសិក្សាក្នុងម៉ោងសិក្សានីមួយៗ។ វិធីនេះអាចប្រើប្រាស់នៅចុងម៉ោងសិក្សាសម្រាប់និស្សិតដើម្បីផ្តល់យោបល់ត្រឡប់ដល់គ្រូ ទាក់ទងជាមួយវគ្គសិក្សា។ វិធីនេះក៏អាចប្រើប្រាស់ដោយគ្រូ ដើម្បីឆ្លុះបញ្ចាំងលើការបង្រៀន និងវគ្គសិក្សារបស់ខ្លួនបានផងដែរ។

កំណត់ហេតុឆ្លុះបញ្ចាំង គឺប្រហាក់ប្រហែលជាមួយសៀវភៅកំណត់ហេតុប្រចាំថ្ងៃ ដែលអាចរៀបចំឡើងដោយនិស្សិត ដើម្បីកត់ត្រាលទ្ធផលការរៀនសូត្រសំខាន់ៗនៅចុងវគ្គបង្រៀន។ វិធីនេះក៏អាចរួមបញ្ចូលសំណួរទាំងឡាយណាដែលសិស្សមាន ដែលអាចយកមកពិភាក្សានៅម៉ោងសិក្សាលើកក្រោយបានផងដែរ។ ពុំចាំបាច់ត្រូវប្រគល់កំណត់ហេតុឆ្លុះបញ្ចាំងទៅឱ្យគ្រូបណ្តុះបណ្តាលទេ។ ដើម្បីលើកទឹកចិត្តការប្រើប្រាស់កំណត់ហេតុឆ្លុះបញ្ចាំង គ្រូឧទ្ទេសអាចរៀបចំ និងចែករំលែកឧទាហរណ៍មួយអំពីសំណេរដែលត្រូវសរសេរបញ្ចូលក្នុងកំណត់ហេតុឆ្លុះបញ្ចាំងនៅដើមវគ្គសិក្សា។

ចំណងជើងកំណត់ហេតុឆ្លុះបញ្ចាំងអាចរួមមានចំណងជើងនានា អាស្រ័យទៅតាមថ្នាក់នីមួយៗ និងរបៀបបង្រៀនរបស់គ្រូឧទ្ទេស ដូចឧទាហរណ៍ខាងក្រោម៖

បញ្ហាសំខាន់ៗដែលត្រូវបានពិភាក្សាក្នុងថ្ងៃនេះមាន៖

ខ្ញុំបានលើកឡើងនូវមតិដូចខាងក្រោមនៅក្នុងថ្នាក់រៀន៖

ខ្ញុំបានសួរសំណួរដូចខាងក្រោមនៅក្នុងថ្នាក់រៀន៖

ខ្ញុំបានឆ្លើយតបសំណួរដូចខាងក្រោម ដែលគ្រូបានសួរ

ខ្ញុំពិបាកយល់ចំណុចដូចខាងក្រោម៖

ខ្ញុំនឹងស្រាវជ្រាវលើបញ្ហាដូចខាងក្រោមមុនពេលម៉ោងរៀនលើកក្រោយ៖

ខ្ញុំនឹងពិភាក្សាបញ្ហាខាងក្រោមជាមួយមិត្តរួមថ្នាក់មុនម៉ោងរៀនលើកក្រោយ៖

ខ្ញុំនឹងសួរគ្រូឧទ្ទេសឱ្យបកស្រាយបញ្ជាក់ចំណុចខាងក្រោមនៅម៉ោងរៀនលើកក្រោយ។

## ការប្រើប្រាស់កំណត់ហេតុឆ្លុះបញ្ចាំងនៅក្នុងវគ្គសិក្សា TTT

សម្រាប់វគ្គបណ្តុះបណ្តាលគ្រូបង្គោល (TTT) នេះ យើងខ្ញុំសូមផ្តល់យោបល់ថា កំណត់ហេតុឆ្លុះបញ្ចាំងគួរត្រូវបានប្រើប្រាស់តាមរយៈការសរសេរបញ្ចូលនូវរាល់វគ្គសិក្សា ដូចមានបង្ហាញក្នុងកម្មវិធីសិក្សា ហេតុនេះសិក្ខាកាមទាំងអស់ត្រូវបានលើកទឹកចិត្តឱ្យឆ្លុះបញ្ចាំងលើបញ្ហាដូចៗគ្នា។ បន្ទាប់មក កំណត់ហេតុឆ្លុះបញ្ចាំងនេះ អាចត្រូវបានប្រើប្រាស់សម្រាប់ការផ្តល់យោបល់ត្រឡប់ និងការវាយតម្លៃនៅចុងបញ្ចប់ថ្ងៃនីមួយៗ ក៏ដូចជាការត្រៀមការវាយតម្លៃជាលាយលក្ខណ៍អក្សរ និងការពិភាក្សានៅក្នុងពេលបិទវគ្គ។

សំណេរដាក់បញ្ចូលសង្ខេបនៅចុងវគ្គសិក្សានីមួយៗ គួរឆ្លើយតបតាមមាតិការបស់វគ្គសិក្សា និងវិធីសាស្រ្តបង្រៀនដែលត្រូវបានយកមកអនុវត្ត។ យើងខ្ញុំក៏ស្នើសុំឱ្យអ្នកកត់ត្រាទុកនូវរាល់គំនិតដែលអ្នកមានកើតចេញពីវគ្គសិក្សាដោយឡែកណាមួយ ទាក់ទងជាមួយថាតើអ្នកនឹងបង្រៀនខុសប្លែកពីវិធីដែលគ្រូបណ្តុះបណ្តាលធ្វើយ៉ាងណាខ្លះ។ សិក្ខាកាមនឹងត្រូវបានស្នើសុំឱ្យចែករំលែកការឆ្លុះបញ្ចាំងមួយចំនួនរបស់ខ្លួនក្នុងវគ្គសិក្សាទី ១៥។

ដើម្បីសម្របសម្រួលដំណើរការនេះ យើងបានរៀបចំឯកសារមួយទំព័រក្នុងមួយថ្ងៃក្នុងឯកសារនេះ។ យើងខ្ញុំសូមស្នើឱ្យអ្នកកត់ត្រាចំណាប់អារម្មណ៍របស់អ្នកដោយសង្ខេបសម្រាប់វគ្គសិក្សានីមួយៗ។

ថ្ងៃទី ១៖ ថ្ងៃ ច័ន្ទ ទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៧

| វគ្គសិក្សា និងម៉ោង | សកម្មភាព | យោបល់ |
|---|---|---|
| វគ្គសិក្សាទី ១<br>៨.៣០ - ១០.៣០ | កម្មវិធីបើក + សេចក្តីផ្តើមអំពីវគ្គសិក្សា TTT | |
| វគ្គសិក្សាទី ២A<br>១១:០០- ១១.២០ | ការស្តាបនាជើងឯកផ្នែកនីតិបរិស្ថាន | |
| វគ្គសិក្សាទី ២B<br>១១.២០-១២.៣០ | បញ្ហាបរិស្ថាននៅកម្រិតសកល ថ្នាក់តំបន់ និងថ្នាក់ជាតិ | |
| វគ្គសិក្សាទី ៣<br>១.៣០-២.១០ | សេចក្តីព្រាងលំហាត់ស្តីពីនិយមន័យ "បរិស្ថាន"? | |
| ២.១០-៣.០០ | សេចក្តីផ្តើមអំពីនីតិបរិស្ថាន<br><br>+ ការពិភាក្សាក្រុមតូចទម្រង់សេរី | |

| | | |
|---|---|---|
| | | |
| វគ្គសិក្សាទី ៤<br><br>៣.៣០-៤.៤៥ | ការធ្វើផែនការ (ទីតាំង) បរិស្ថាន និងច្បាប់ EIA<br><br>+ ការពិភាក្សាក្រុមតូច | |
| ៤.៤៥ – ៥.១៥ | ករណីសិក្សា៖ ទំនប់បាគុណ ប្រទេសម៉ាឡេស៊ី | |

ការឆ្លុះបញ្ចាំងទូទៅលើថ្ងៃទី ១៖

ថ្ងៃទី ២៖ ថ្ងៃ អង្គារ៍ ទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៧

| វគ្គសិក្សា និងម៉ោង | សកម្មភាព | យោបល់ |
|---|---|---|
| វគ្គសិក្សាទី ៥<br><br>៩.០០-១០.០៥ | ទិដ្ឋភាពទូទៅនៃច្បាប់ការពារបរិស្ថាន<br>+<br>ការពិភាក្សាក្រុមតូច | |
| ១០.០៥-១០.៤៥ | ឯកសារបង្រៀនស្តីពីការគ្រប់គ្រងកាកសំណល់ | |
| វគ្គសិក្សាទី ៦<br><br>១១.០០-១២.០០ | ទិដ្ឋភាពទូទៅនៃជីវៈចម្រុះ/ច្បាប់បេតិកភណ្ឌធម្មជាតិ និងបេតិកភណ្ឌវប្បធម៌<br><br>+ ការពិភាក្សាក្រុមតូច | |
| ១២.០០-១២.១៥ | វីដេអូអំពីបេតិកភណ្ឌ | |
| ១២.១៥-១២.៣០ | ការពិភាក្សាក្នុងថ្នាក់ទម្រង់សេរី៖ តើអ្វីគួរមានតម្លៃទទួលបានការការពារនៅក្នុងយុត្តាធិការរបស់អ្នក? | |
| វគ្គសិក្សាទី ៧ | ទិដ្ឋភាពទូទៅស្តីពីច្បាប់ | |

| | | |
|---|---|---|
| ១.៣០-២.៣០ | គ្រប់គ្រងធនធានធម្មជាតិ<br><br>+ ការពិភាក្សាក្រុមតូច | |
| ២.៣០-៣.១៥ | ការសំដែងតួ (ផ្នែកទី ១)៖ ពិពណ៌នាលក្ខណៈសម្បត្តិនៃលំហាត់សំដែងតួ និង ការកំណត់ក្រុម | |
| វគ្គសិក្សាទី ៨<br><br>៣.៤៥-៤.១៥ | ច្បាប់ស្តីពីការប្រែប្រួលអាកាសធាតុ និងថាមពលស្អាត | |
| ៤.១៥-៥.០៥ | លំហាត់ការបំផុសគំនិតដោយមានការណែនាំ | |
| ៥.០៥-៥.១៥ | វគ្គផ្តល់យោបល់ត្រឡប់៖ សិក្ខាកាមដែលជាអ្នកសម្របសម្រួលធ្វើការឆ្លុះបញ្ចាំងលើកិច្ចខិតខំរបស់ខ្លួន<br>សិស្សផ្តល់យោបល់ត្រឡប់ក្នុងលក្ខណៈស្ថាបនាដល់អ្នកសម្របសម្រួល<br>យោបល់ត្រឡប់របស់គ្រូបណ្តុះបណ្តាលដល់សិស្ស | |

| | | |
|---|---|---|
| | និងអ្នកសម្របសម្រួល | |
| ៥.១៥-៥.៣០ | ការចែកលំហាត់ស្រាវជ្រាវ MEA | |

ការឆ្លុះបញ្ចាំងទូទៅលើថ្ងៃទី ២៖

ថ្ងៃទី ៣៖ ថ្ងៃ ពុធ ទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៧

| | | |
|---|---|---|
| វគ្គសិក្សាទី ៩<br><br>៩.០០ -៩.៥០ | បទបង្ហាញដោយគ្រូឧទ្ទេសជាភ្ញៀវ៖ តួនាទីរបស់តុលាការ<br><br>+ សំណួរ និងចម្លើយ | |
| ៩.៥០ – ១០.៣០ | បទបង្ហាញ៖ បណ្តឹងវិវាទផ្នែកបរិស្ថាន ដោយមើលចេញពីទស្សនវិស័យបែបប្រៀបធៀប<br><br>+ សំណួរ និងចម្លើយ | |
| វគ្គសិក្សាទី ១០<br><br>១១.១០-១១.៤០ | សិទ្ធិនៅក្នុងច្បាប់បរិស្ថាន<br><br>+ សំណួរ និងចម្លើយ | |
| ១១.៤០-១២.៣០ | គ្លីនិកបរិស្ថាន៖ បទបង្ហាញ<br><br>+ ការពិភាក្សាដោយមាន | |

| | | |
|---|---|---|
| | រចនាសម្ព័ន្ធជាក្រុមតូចៗ | |
| វគ្គសិក្សាទី ១១<br><br>១.៣០ - ២.១០ | ច្បាប់បរិស្ថានអន្តរជាតិ | |
| ២.១០ - ២.៣០ | ដំណើរការដើម្បីផ្តល់សច្ចាប័នលើសន្ធិសញ្ញាក្នុងប្រទេសកម្ពុជា/ប្រទេសថៃ | |
| ២.៣០ – ៣.០០ | លំហាត់ការស្រាវជ្រាវ MEA៖ បទបង្ហាញលំហាត់សរសេរស្តីពីការអនុវត្ត MEA ក្នុងប្រទេសកម្ពុជា/ប្រទេសឡាវ | |
| វគ្គសិក្សាទី ១២<br><br>៣.៣០-៤.៣០ | សិក្ខាកាមចូលរួមក្នុងការចាត់ចែងតួនាទីសម្រាប់លំហាត់សន្ទានកម្មដូចការពិត | |
| ៤.៣០- ៥.០០ | ការពិភាក្សាក្នុងថ្នាក់៖ យោបល់ត្រឡប់ចំពោះដំណើរការសន្ទានកម្ម៖ មតិរិះគន់លើគុណតម្លៃនៃសន្ទានកម្ម<br>+<br>ការពិភាក្សាស្តីពីរបៀបធ្វើយ៉ាងណាដើម្បីឱ្យសិក្ខាកាមអាចដាក់ | |

| | | |
|---|---|---|
| | បញ្ចូលការសំដែងតួនៅក្នុងវគ្គសិក្សាស្តីពីច្បាប់បរិស្ថាន។ | |

ការឆ្លុះបញ្ចាំងទូទៅចំពោះថ្ងៃទី ៣៖

ថ្ងៃទី ៤ ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៧

| វគ្គសិក្សា និងម៉ោង | សកម្មភាព | យោបល់ |
|---|---|---|
| វគ្គសិក្សាទី ១៣<br><br>៩.០០ – ៩.៣០ | ច្បាប់បរិស្ថានថ្នាក់តំបន់<br><br>+ សំណួរ និងចម្លើយ | |
| ៩.៣០-១០.០០ | ករណីសិក្សា៖ ការកំពប់ប្រេងនៅ Timor Sea Montara | |
| ១០.០០ – ១០.៣០ | ករណីសិក្សា៖ ឧទ្យាន Great Limpopo Transfrontier | |
| វគ្គសិក្សាទី ១៤<br>១១.០០ – ១១.១០ | ការតាក់តែងវគ្គសិក្សាច្បាប់បរិស្ថាន៖ ការពិនិត្យឡើងវិញលើវិធីសាស្ត្របង្រៀន | |
| ១១.១០ – ១១.៤០ | ការពិភាក្សាអំពីគោលវិធីផ្អែកលើបច្ចេកវិទ្យា | |
| ១១.៤០ – ១២.៣០ | វគ្គសិក្សាបែបសិក្ខាសាលាស្តីពីវិធីសាស្ត្របង្រៀន | |

| | | |
|---|---|---|
| | | |
| វគ្គសិក្សាទី ១៥ និង ១៦៖ ដំណើរទស្សនកិច្ចសិក្សា<br><br>១.១៥-១.៣០ | បទបង្ហាញដំណើរទស្សនកិច្ចសិក្សា | |
| ១.៣០-៤.៣០ | ដំណើរទស្សនកិច្ចសិក្សា៖ មជ្ឈមណ្ឌលអង្គរសម្រាប់ការអភិរក្សជីវៈចម្រុះ | |
| ៤.៣០-៥.៣០ | វគ្គផ្តល់យោបល់ក្រោយការធ្វើសកម្មភាព៖ ការពិភាក្សាអំពីបញ្ហាផ្នែកច្បាប់កើតចេញពីទស្សនកិច្ចសិក្សា ការពិភាក្សាអំពីដំណើរទស្សនកិច្ចសិក្សាជាវិធីសាស្ត្របង្រៀន | |

ការឆ្លុះបញ្ចាំងទូទៅលើថ្ងៃទី ៤៖

## ថ្ងៃទី ៥ ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៧

| វគ្គសិក្សា និងម៉ោង | សកម្មភាព | យោបល់ |
|---|---|---|
| វគ្គសិក្សាទី ១៧<br><br>៩.០០ – ៩.១៥ | តួនាទីនៃការវាយតម្លៃ | |
| ៩.១៥ - ៩.៣០ | ជម្រើសនៃការវាយតម្លៃ | |
| ៩.៣០-១០.៣០ | ចំណូលចិត្តសម្រាប់ជម្រើសការវាយតម្លៃៈ ទម្រង់សេរី ការពិភាក្សាក្រុមតូចបែបស្ទ័យ តម្រង់ទិស | |
| វគ្គសិក្សាទី ១៨<br>១១.០០ -១២.៣០ | លំហាត់ការតាក់តែងៈ គ្រោងវគ្គសិក្សាស្តីពីច្បាប់បរិស្ថាន | |
| វគ្គសិក្សាទី ១៩<br><br>១.៣០ -២.០០ | បទបង្ហាញស្តីពីគ្រោង និងយោបល់ត្រឡប់ក្នុងក្រុមតូច | |
| ២.០០-២.៣០ | ការពិភាក្សាទម្រង់សេរីក្រុមធំស្តីពីការតាក់តែងវគ្គសិក្សាស្តីពីច្បាប់បរិស្ថាន | |

| | | |
|---|---|---|
| ២.៣០ – ៣.០០ | បងបង្ហាញអំពី IUCNAEL និង IUCN WCEL | |
| វគ្គសិក្សាទី ២០<br><br>៣.៣០-៣.៤៥ | វគ្គជើងឯក៖ ការបង្កើតបណ្តាញជើងឯកផ្នែកនីតិបរិស្ថាន | |
| ៣.៤៥-៤.១៥ | ការពិភាក្សាក្នុងថ្នាក់អំពីលទ្ធផលវគ្គសិក្សា | |
| ៤.១៥ – ៤.៣០ | ការបំពេញទម្រង់វាយតម្លៃវគ្គសិក្សាដោយសិក្ខាកាម | |
| ៤.៣០ - ៥.០០ | ពិធីបិទវគ្គ | |

ការឆ្លុះបញ្ចាំងទូទៅលើវគ្គសិក្សា៖